ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ២២០៥
ចុះថ្ងៃទី ១៦.០៧.២០១២
សាលក្រម
លេខ ៨៦ "យ"
ចុះថ្ងៃទី ២២.១០.២០១៣

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៣ ដែលមានសមាសភាព ជំនុំជម្រះដូចតទៅ ៖

### ចៅក្រមជំនុំជំម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ជាក្រឡាបញ្ជីអមសាលាដំបូងរាជធានីភ្នំពេញ

### ដើម្បីជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌលេខ ២២០៥ ចុះថ្ងៃទី ១៦.០៧.២០១២ ដែលមានជនជាប់ចោទ ៖

ឈ្មោះ [redacted] ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅសង្កាត់លេខ៥ ក្រុងភ្នំ [redacted] ឪពុកឈ្មោះ [redacted]
ពេញ [redacted] ផ្លូវលេខ [redacted] ។- មានកូន ០២នាក់ ទោស
[redacted] ( រ ) ម្ដាយឈ្មោះ [redacted] ( រ ) ប្រពន្ធឈ្មោះ [redacted]
ពីមុនគ្មាន ជានីតិជន ។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៧៧៩ តព្រ ចុះថ្ងៃទី ១៧.០៦.២០១៣

ជាប់ចោទពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញកាលពីថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

មេធាវី [redacted] វិស្សុត និងមេធាវី [redacted] សុជាតិ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ (អវត្តមាន)

ដើមបណ្ដឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] ភេទប្រុស អាយុ ៤០ឆ្នាំ សញ្ជាតិខ្មែរ អាស័យដ្ឋានផ្ទះលេខ [redacted] ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៥០៧ អ.យ.ព ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំរឿងទៅជំនុំជម្រះលេខ ២៦៤៧ ដជរ ចុះថ្ងៃទី ២៣.០៨.១៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

### នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ស៊ុនឡេង បានឆ្លើយថា ៖ នៅឆ្នាំ ២០១១ ខ្ញុំជាតំណាងឲ្យក្រុមហ៊ុន ហើយខ្ញុំជានាយកផ្នែកហិរញ្ញវត្ថុ Rocksteel ដោយធ្វើការផ្គង់ផ្គង់ប្រេងនៅខេត្តក្រចេះ ។ អតិថិជនមានការគៅជាមួយខ្ញុំបាទដោយខ្ញុំនៅជំពាក់ជាមួយអតិថិជននៅខេត្តក្រចេះ ។ ដោយខ្ញុំខ្វះហិរញ្ញវត្ថុក្នុងក្រុមហ៊ុន ដូច្នេះខ្ញុំត្រូវទាមទារសំណង



Scanned by CamScanner

ពីក្រុមហ៊ុនសងទៅគាត់វិញ [redacted] ប៉ុន្តែដោយសារគាត់រង់ចាំយូរពេក ទើបគាត់អស់ជំនឿលើប្ដីខ្ញុំ ដាក់ពាក្យបណ្ដឹង ប្ដីខ្ញុំ ។ [redacted] ត្រឹម ជាម្ចាស់ក្រុមហ៊ុន Rocksteel គាត់ជាអ្នកស៊ីញ៉េសែក ។ ហើយខ្ញុំជាអ្នកតំណាង ។ នៅខ្វះប្រាក់ ចំនួន ៣ម៉ឺនដុល្លា ដែលក្រុមហ៊ុនបានចេញសែកឲ្យគេ ។ រយៈពេលរាប់ខែក្រោយការផ្គត់ផ្គង់ ទើបទូទាត់សែក ហើយរាល់ដងផ្គត់ផ្គង់ភ្លាម ទុករយៈពេល ៣០ថ្ងៃ ទៅបើកប្រាក់ ។ សែក ៣ម៉ឺន ២ពាន់ដុល្លា គឺឈ្មោះ [redacted] ត្រឹម ជាអ្នកស៊ីញ៉េ ហើយខ្ញុំមិនមានសិទ្ធិស៊ីញ៉េទេ ។ ក្នុងនាមក្រុមហ៊ុនជាអ្នកទិញ ខ្ញុំជាអ្នកចុះកិច្ចសន្យា ។ នៅជំពាក់ក្រុមហ៊ុន ៣ម៉ឺន ទើបខាងខ្ញុំជាអ្នកប្រគល់សែកឲ្យគាត់។ ពីមុនមាន [redacted] ហាក់មុង ជាអ្នកបញ្ជាទិញ តាមរយៈទូរស័ព្ទ ខ្ញុំមិនបានបញ្ជាទិញទេ ។

-ក្រឡាបញ្ជីបានអានកំណត់ហេតុសួរចម្លើយជនជាប់ចោទនៅអយ្យការ និងចៅក្រមស៊ើបសួរ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា ខ្ញុំតំណាងអោយក្រុមហ៊ុន L.H.R ផ្គត់ផ្គង់ប្រេង។ ខ្ញុំប្ដឹងឈ្មោះ [redacted] ស៊ិនឡេង បានចេញសែកអត់ប្រាក់ ។ ឈ្មោះ [redacted] ស៊ិនឡេង បានមកចំនាក់ចំនងទិញប្រេងនៅក្រុមហ៊ុន ដោយឈ្មោះគាត់ជាអ្នកទិញ ដោយចូលកំឡុងខែ១២ ឈ្មោះ [redacted] ស៊ិនឡេង បានគេចវេសមិនព្រមសងលុយខ្ញុំ ហើយទូរស័ព្ទមិនលើក ។ គ្មានក្រុមហ៊ុនណាក្រៅពីគាត់ទេ ។ ហើយសួរគាត់មានលទ្ធភាពសងពេលណា គាត់ក៏ចេញសែកឲ្យខ្ញុំ នៅថ្ងៃទី ១០.០២.២០១២ រហូតកំណត់ថ្ងៃកំណត់បើកលុយ គាត់នៅតែមិនព្រមសងលុយខ្ញុំទៀត ។ នៅពេលដែលខ្ញុំបានទទួលដំណឹងថា [redacted] ស៊ិនឡេង ត្រូវគេចាប់ខ្លួន និងឃុំខ្លួន ។ ហើយមេធាវីបានព្យាយាមមកសំរុះសំរួលគ្នា ប៉ុន្តែចេះតែដាក់ពាក្យសុំពន្យាចេះចុះមិនប្រាកដនោះទេ ។ សែកនេះគឺឈ្មោះ [redacted] ស៊ិនឡេង ជាអ្នកយកសែកមកស៊ីញ៉េ ហើយខ្ញុំបានទៅសួរធនាគារបានប្រាប់ថា សែកនេះអត់លុយ ។ ឈ្មោះ [redacted] ស៊ិនឡេង ហើយប្រាប់ខ្ញុំ ហើយខ្ញុំបានទទួលពីឈ្មោះ [redacted] ស៊ិនឡេង ។ ដូច្នេះសូមទាមទារប្រាក់ចំនួន ៣២២០១ដុល្លាអាមេរិក សំណងជម្ងឺចិត្ត ៥០០០ដុល្លាអាមេរិក ការប្រាក់តាមច្បាប់ និងសុំផ្ដន្ទាទោសតាមច្បាប់ ។

-ក្រឡាបញ្ជីអានលិខិតបង្វិលមូលប្បទានប័ត្រក្រឡប់ ។

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ

ឆ្លងតាមសវនាការរួចមក យល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើចេញសែកអត់លុយឲ្យទៅដើមបណ្ដឹងប្រាកដមែន ដូច្នេះតំណាងអយ្យការសម្រេចតំកល់ការចោទប្រកាន់ និងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឲ្យផ្ដន្ទាទោសតាមច្បាប់ ។

ជនជាប់ចោទសំណូមពរ បដិសេធការចោទប្រកាន់របស់ដើមបណ្ដឹង និងសូមរក្សាសំណូមពរបណ្ដឹងគប។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់អំណានលិខិតមូលប្បទានប័ត្រក្រឡប់

-ក្រោយពីបានស្ដាប់តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារផ្សេងៗក្នុងសំណុំរឿង

## **សំអាងហេតុ**

១-កាលពីថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១២ ស្ថិតនៅចំណុចរាជធានីភ្នំពេញ ពិតជាមានករណី ចេញមូលប្បទានប័ត្រចំនួនមួយសន្លឹក ដោយគ្មានសាច់ប្រាក់ក្នុងគណនី ប្រាកដមែន ដោយមានមូលប្បទានប័ត្រលេខ ០២៩០៥៨ ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ស៊ិនឡេង ប្រាកដមែន ។

២-ជនជាប់ចោទបានឆ្លើយនៅពេលសវនាការថា ខ្លួនពិតជាបានប្រគល់សែកមួយសន្លឹកមានចំនួនទឹកប្រាក់ ៣ម៉ឺន ២ពាន់ ដុល្លារអាមេរិក ប្រាកដមែន ដើម្បីទូទាត់ថ្លៃប្រេងអោយក្រុមហ៊ុន L.H.R ទៅអោយឈ្មោះ [redacted]



Scanned by CamScanner

[redacted] ជាតំណាងអោយក្រុមហ៊ុនប្រេងក៏ប៉ុន្តែសែកនោះខ្លួនមិនមែនជាអ្នកស៊ីញ៉េសែកនោះទេ គឺឈ្មោះ: [redacted] ត្រើ ជាម្ចាស់ក្រុមហ៊ុន Rocksteel ជាអ្នកស៊ីញ៉េសែក ។ ដោយផ្អែកតាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ: ត្រឹ [redacted] បានឆ្លើយថា ខ្លួនបានទទួលសែកមួយសន្លឹកដែលមានទឹកប្រាក់ ៣២២០១ ដុល្លារអាមេរិក ពីឈ្មោះ: [redacted] ស៊ិនឡេង ដោយផ្ទាល់ដែលជាការការទូទាត់ថ្លៃប្រេង ហើយឃើញដោយផ្ទាល់ឈ្មោះ: [redacted] ស៊ិនឡេង ជាអ្នកស៊ីញ៉េសែកនោះដោយខ្លួនឯង ហើយនៅមិនអស់ចិត្តខ្លួនបានសុំអត្តសញ្ញាណប័ណ្ណឈ្មោះ: [redacted] ស៊ិនឡេង ថតចំលងទុកថែមទៀត ។ ដូច្នេះដោយពិចារណាលើការឆ្លើយទាំងពីរខាងលើ ឃើញថា តាមការត្រួតពិនិត្យលើហត្ថលេខារបស់ឈ្មោះ: [redacted] ត្រឹម តាមរយៈពាក្យបណ្ដឹងតបរបស់ឈ្មោះ: [redacted] ស៊ិនឡេង និងមូលប្បទានប័ត្រខាងលើនេះគឺមានការខុសគ្នា ហើយណាមួយបូករួមទាំងចម្លើយបញ្ជាក់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណី បានបង្ហាញឲ្យឃើញថាចម្លើយរបស់ជនជាប់ចោទឈ្មោះ: [redacted] ស៊ិនឡេង ជាចម្លើយដោះសារ គ្មានភស្តុតាងណាមួយដែលអាចបង្ហាញឲ្យស៊ីសង្វាក់បាន ។

៣-អំពើរបស់ជនជាប់ចោទឈ្មោះ: [redacted] ស៊ិនឡេង ពិតជាបានចេញមូលប្បទានប័ត្រមួយសន្លឹកទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ: [redacted] ដោយគ្មានសាច់ប្រាក់ក្នុងគណនី ប្រាកដមែន ដោយឈ្មោះ: [redacted] ស៊ិនឡេង បានចេញមូលប្បទានប័ត្របញ្ជាទិញប្រេងពីក្រុមហ៊ុន L.H.R ហើយពេលក្រុមហ៊ុនបានទទួលបញ្ជាទិញដោយការប្រគល់មូលប្បទានប័ត្រនោះ ខាងក្រុមហ៊ុនបានបញ្ចេញប្រេងទៅតាមការបញ្ជាទិញរបស់ឈ្មោះ: [redacted] ស៊ិនឡេង ប៉ុន្តែដល់ពេលទៅបើកប្រាក់ក្នុងមូលប្បទានប័ត្រ ខាងធនាគារបង្វិលមូលប្បទានប័ត្រមកវិញ ថាគ្មានសាច់ប្រាក់នោះទេ ។ ដូច្នេះអំពើរបស់ជនជាប់ចោទ គឺជាការមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបានដែលបានធ្វើឲ្យខូចប្រយោជន៍ដើមបណ្ដឹង ។ ដូច្នេះអំពើរបស់ជនជាប់ចោទឈ្មោះ: [redacted] ស៊ិនឡេង បានរំលោភទៅលើមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

៤-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ: [redacted] ឡៃស៊ាប បានប្ដឹងទាមទារសំណងចំនួន ៣២២០១ដុល្លា(បីម៉ឺនពីរពាន់ពីររយមួយដុល្លាអាមេរិក) និងជម្ងឺចិត្តចំនួន ៥០០០ដុល្លា(ប្រាំពាន់ដុល្លាអាមេរិក) គប្បីតុលាការពិចារណាដល់បញ្ហានេះ ។

៥-លោកតំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើចេញសែកអត់លុយឲ្យទៅដើមបណ្ដឹងប្រាកដមែន ដូច្នេះតំណាងអយ្យការសម្រេចតំកល់ការចោទប្រកាន់ និងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឲ្យផ្ដន្ទាទោសតាមច្បាប់ គប្បីតុលាការពិចារណាតាមផ្លូវច្បាប់ ។

៦-សំដីចុងក្រោយរបស់ជនជាប់ចោទបានសុំបដិសេធការចោទប្រកាន់របស់ដើមបណ្ដឹង និងសូមរក្សាសំណូមពរបណ្ដឹងតប ។ គប្បីតុលាការពិចារណាតាមច្បាប់ ។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ: [redacted] ស៊ិនឡេង ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

**ហេតុដូច្នេះសម្រេច**

១/ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ: [redacted] ស៊ិនឡេង ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ឆ្នាំ ០៦ខែ គិតចាប់ពីថ្ងៃចាប់ឃុំខ្លួន ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១២ តាមមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

២/បង្គាប់ឲ្យជនជាប់ចោទឈ្មោះ: [redacted] ស៊ិនឡេង សងសំណងការខូចខាតចំនួន ៣២២០១ ដុល្លា(បីម៉ឺនពីរពាន់ពីររយមួយដុល្លាអាមេរិក) និងសំណងជម្ងឺចិត្តចំនួន ១០០០ដុល្លា(មួយពាន់ដុល្លាអាមេរិក) ទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ: [redacted] ពេលសាលក្រមចូលស្ថាពរ ។ ការទាមទារលើសពីនេះច្រានចោល ។



Scanned by CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈ ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។ ទុកសិទ្ធប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted] ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**

**ចៅក្រម**

[redacted]

·បានចម្លងត្រឹមត្រូវតាមច្បាប់ដើម·

ភ្នំពេញ ថ្ងៃទី 1២ ខែធ្នូ ឆ្នាំ២០១៣

**ក្រឡាបញ្ជី**

[redacted]



Scanned by CamScanner